ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ខ្លឹមសារផ្តល់ជូនអ្នកសារព័ត៌មានស្តីពី**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជំនួបសម្តែងការគួរសម និងជម្រាបលាពី**
**ឯកឧត្តម ចូ ស្ទយ័រ (Jo Scheuer) អ្នកសម្របសម្រួលប្រព័ន្ធអង្គការសហប្រជាជាតិប្រចាំកម្ពុជា**

**រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៦ - ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជំនួបសម្តែងការគួរសម និងជម្រាបលាពី **ឯកឧត្តម ចូ ស្ទយ័រ** អ្នកសម្របសម្រួលប្រព័ន្ធអង្គការសហប្រជាជាតិ (អ.ស.ប.) ប្រចាំកម្ពុជា ក្នុងឱកាសដែលឯកឧត្តមបញ្ចប់អាណត្តិបេសកកម្មនៅកម្ពុជា។

នៅក្នុងជំនួបនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការកោតសរសើរចំពោះការរួមចំណែកដ៏មានតម្លៃ និងកិច្ចខិតខំប្រឹងប្រែងរបស់**ឯកឧត្តម ចូ ស្ទយ័រ** ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយភ្នាក់ងារ អ.ស.ប. ប្រចាំកម្ពុជា និងក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសង្កត់ធ្ងន់ពីតម្លៃនៃសន្តិភាពដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍជាតិ ហើយសង្ឃឹមថា សហគមន៍អន្តរជាតិនឹងបន្តគាំទ្រ កម្ពុជាដែលជាប្រទេសតូច ស្រលាញ់សន្តិភាព និងចង់បានតែសន្តិភាពជាមួយនឹងប្រទេសជិតខាងដើម្បីឱ្យប្រជាជនទាំងសងខាងរស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងនូវអំណរគុណចំពោះ អ.ស.ប. ក្នុងការចូលរួមចំណែកយ៉ាងសកម្មក្នុងសកម្មភាពមីនក្រោមប្រតិបត្តិការរក្សាសន្តិភាព។ កម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះភាពជាដៃគូជាមួយ អ.ស.ប. ក្នុងវិស័យនេះ ដោយទទួលស្គាល់នូវការរួមចំណែករបស់ អ.ស.ប. ក្នុងការជំរុញគោលបំណងមនុស្សធម៌ ការការពារជនស៊ីវិល និងការគាំទ្រកិច្ចប្រឹងប្រែងរក្សាសន្តិភាពអន្តរជាតិ។

**ឯកឧត្តម ចូ ស្ទយ័រ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ក្នុងអំឡុងបេសកកម្មការងាររបស់ឯកឧត្តម។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ភាពជាដៃគូនេះបានអនុញ្ញាតឱ្យប្រព័ន្ធ អ.ស.ប. អាចផ្តល់នូវការគាំទ្រកាន់តែមានប្រសិទ្ធភាពលើវិស័យជាច្រើន។ ឯកឧត្តមបានគូសបញ្ជាក់បន្ថែមអំពីវឌ្ឍនភាពរបស់កម្ពុជា ក្នុងការតម្រង់អាទិភាពជាតិ ឱ្យស្របទៅនឹងរបៀបវារៈអភិវឌ្ឍន៍សកល ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជា ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។ ឯកឧត្តម ចូ ស្ទយ័រ ក៏បានបង្ហាញសុទិដ្ឋិនិយមចំពោះការអភិវឌ្ឍនាពេលអនាគតរបស់ប្រទេសកម្ពុជាផងដែរ។

ទន្ទឹមនឹងនេះ **ឯកឧត្តម ចូ ស្ទយ័រ** ក៏បានទទួលស្គាល់នូវកេរដំណែលដ៏មានអត្ថន័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដោយទទួលស្គាល់ថា វាជាគ្រឹះដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ក្នុងការជំរុញយុត្តិធម៌ ការទទួលខុសត្រូវ និងការផ្សះផ្សាជាតិ។ កេរដំណែលរបស់ ECCC គឺជាមូលដ្ឋានគ្រឹះសម្រាប់កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជាក្នុងការពង្រឹងនីតិរដ្ឋ ការអភិរក្សអង្គចងចាំប្រវត្តិសាស្ត្រ និងការបង្កើតមូលដ្ឋានគ្រឹះអចិន្ត្រៃយ៍សម្រាប់សន្តិភាព និងការអភិវឌ្ឍស្ថាប័នក្នុងប្រទេស។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម ចូ ស្ទយ័រ** បានសម្តែងនូវសមានចិត្តអាណិតចំពោះប្រជាជនភៀសសឹកកម្ពុជា និងជនរងគ្រោះ ដែលរងការប៉ះពាល់ដោយជម្លោះព្រំដែនកម្ពុជា-ថៃ។ ឯកឧត្តមបានបញ្ជាក់ជាថ្មីឡើងវិញ

ពីសាមគ្គីភាពជាមួយសហគមន៍ដែលទទួលរងការប៉ះពាល់ និងពីការប្តេជ្ញាចិត្តជាបន្តរបស់ អ.ស.ប. ក្នុងការគាំទ្រដល់តម្រូវការមនុស្សធម៌ ការការពារ និងកិច្ចខិតខំប្រឹងប្រែង ក្នុងគោលបំណងលើកកម្ពស់សន្តិភាព ស្ថិរភាព និងសុវត្ថិភាពមនុស្ស។ ឯកឧត្តម ក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាចលករក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់សន្តិភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ស្របតាមអាទិភាពជាតិរបស់កម្ពុជា និងតួនាទីសកលរបស់អង្គការសហប្រជាជាតិ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការធ្វើការជិតស្និទ្ធជាមួយ អ.ស.ប. ជាពិសេស អ្នកសម្របសម្រួលប្រព័ន្ធ អ.ស.ប. ថ្មី ប្រចាំកម្ពុជា គឺលោកស្រី វ៉ាំងដាំងកា អាន់ឌ្រេវ៉ា។

ជាទីបញ្ចប់ភាគីទាំងពីរ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួម ក្នុងការពង្រឹងបន្ថែមទៀតនូវភាពជាដៃគូយូរអង្វែងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ។

ថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៦